00204519

C22/I/61

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | |
|---|---|
| **សំណុំរឿងលេខ៖** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣) |
| **កាលបរិច្ឆេទនៃឯកសារ៖** | ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ |
| **ភាគីបញ្ជូន៖** | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម៖** | អង់គ្លេស |
| **ប្រភេទឯកសារ៖** | សាធារណៈ |

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងការដាក់ពាក្យសុំឲ្យពិចារណាឡើងវិញ**
**នៅលើសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ**
**ទាក់ទិននឹងសិទ្ធិសវនាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

---

**បញ្ជូនដោយ៖**
**ការិយាល័យសហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក តាន់ សេណារ៉ុង
លោក Anees AHMED

**បញ្ជូនទៅ៖**
**អង្គបុរេជំនុំជម្រះ៖**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ អៀង សារី៖**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 07 / 2008
ម៉ោង (Time/Heure): 14 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

00204520

C22/I/61

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣)

## ១. សេចក្ដីផ្ដើម

១. អង្គបុរេជំនុំជម្រះបានណែនាំដល់គូភាគីឱ្យឆ្លើយតបទៅនឹងពាក្យសុំមួយដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីមួយរូប ស្នើឱ្យមានការពិចារណាឡើងវិញចំពោះសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងការបដិសេធសិទ្ធិសវនាការដោយបុគ្គលផ្ទាល់ដែលគេបានអះអាង [1]។ អង្គជំនុំជម្រះបានកត់សំគាល់ឃើញថា ពាក្យសុំនេះដែលត្រូវបានដាក់ជូនដោយសុពលភាពនៅក្រោយពេលបញ្ចប់សវនាការគួរតែត្រូវបានចាត់ទុកថាជាសំណើមួយសុំសវនាការឡើងវិញដើម្បីស្ដាប់ការលើកឡើងរបស់អ្នកដាក់ពាក្យសុំ[2] ។

២. សហព្រះរាជអាជ្ញាសន្និដ្ឋានថា គោលការណ៍នៃការជំនុំជម្រះក្ដីដោយត្រឹមត្រូវរាប់បញ្ចូលទាំងសិទ្ធិចូលរួមរបស់គូភាគី និងសិទ្ធិឱ្យគេស្ដាប់សវនាការនៅក្នុងករណីផ្ទាល់ខ្លួនរបស់គេ ។ ប៉ុន្តែសិទ្ធិនេះមិនមែនដាច់ខាតនោះទេ ។ តុលាការអាចចាត់ចែងការអនុវត្តសិទ្ធិនោះបាន ។

៣. អង្គហេតុនានានៅក្នុងពាក្យសុំនេះមិនមែនសុំឱ្យមានការបើកសវនាការឡើងវិញទៅលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្ដោះអាសន្ននោះទេ ហើយពាក្យសុំនេះ គួរតែត្រូវបានគេប្រកាសថាមិនទទួលយក ។ ប៉ុន្តែដើម្បីជាប្រយោជន៍ដល់សវនាការផ្សេងៗទៀតនៅថ្ងៃអនាគត អង្គបុរេជំនុំជម្រះអាចពិចារណាបង្កើតឱ្យមានគោលការណ៍ណែនាំផ្សេងៗសំរាប់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីឱ្យមានតុល្យភាពនៃសិទ្ធិរបស់ជនរងគ្រោះសក្ដានុពលជាច្រើននាក់ ដើម្បីពួកគេបានចូលរួមប្រកបដោយអត្ថន័យនៅក្នុងកិច្ចដំណើរការនីតិវិធី និងសិទ្ធិរបស់ចុងចោទទទួលបាននូវកិច្ចដំណើរការនីតិវិធីដោយត្រឹមត្រូវ និង ឆាប់រហ័សសមហេតុផល។ គោលការណ៍ទាំងនោះអាចរាប់បញ្ចូលទាំងសិទ្ធិបញ្ញត្តិរបស់ភាគីដើមបណ្ដឹង

---

[1] *ករណីរបស់ ធៀង សារី* ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសេចក្ដីណែនាំអំពីការដាក់ពាក្យសុំឱ្យអង្គបុរេជំនុំជម្រះ ពិចារណាឡើងវិញអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងចំពោះអង្គជំនុំជម្រះ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣) ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ ERN 001986932-001986933, C22/I/56 [*ចាប់ពីពេលនេះទៅហៅថា សេចក្ដីណែនាំ*] ។

[2] សេចក្ដីណែនាំ, កថាខ័ណ្ឌ៥ ។

រដ្ឋប្បវេណីស្របច្បាប់ដែលគ្មានអ្នកតំណាង សំរាប់ថ្លែងចំពោះអង្គជំនុំជម្រះដោយបុគ្គលខ្លួនឯងផ្ទាល់ ។

## ២. ការដាក់ពាក្យសុំឲ្យពិចារណាឡើងវិញ

*ការពិចារណាឡើងវិញនូវសេចក្ដីសម្រេចត្រូវបានអនុញ្ញាតបានតែក្នុងករណីមួយចំនួនជាក់លាក់តែប៉ុណ្ណោះ*

៤. ដើមបណ្ដឹងរដ្ឋប្បវេណីបានសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាឡើងវិញនូវសេចក្ដីសម្រេចរបស់ខ្លួនទាក់ទងនឹងសិទ្ធិរបស់គាត់ក្នុងការចូលរួមកិច្ចសវនាការដោយផ្ទាល់[3] ។ តុលាការអន្តរជាតិបានដោះស្រាយជ្រះស្រឡះរួចហើយអំពីច្បាប់ទាក់ទងនឹងបញ្ហាពិចារណាឡើងវិញអំពីសេចក្ដីសម្រេចនានា ជាពិសេសសម្រេចដោយតុលាការចុងក្រោយ (ដូចជាអង្គបុរេជំនុំជម្រះនេះដូច្នេះដែរ)។ ឧទាហរណ៍ តុលាការយុត្តិធម៌អន្តរជាតិ(អាយស៊ីជេ)មានអំណាចពិចារណាឡើងវិញតែទៅលើរបកគំហើញនៃអង្គហេតុថ្មីដែលមានលក្ខណៈកំណត់ដែលខ្លួននិងភាគីដើមបណ្ដឹងមិនបានដឹងនៅក្នុងពេលធ្វើសេចក្ដីសម្រេចតែប៉ុណ្ណោះ។[4] ជាងនេះទៅទៀត ក្នុងករណី *Barayagwiza* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដាបានរកឃើញកត្តាសន្ទាន(ភ្ជាប់គ្នា)មួយចំនួនដូចខាងក្រោមដែលត្រូវតែបំពេញឱ្យបានមុនពេលតុលាការនេះធ្វើការសើរើនូវសេចក្ដីសម្រេចរបស់ខ្លួន៖

i. អង្គហេតុនោះត្រូវតែថ្មីដែលភាគីដើមបណ្ដឹងមិនបានដឹងនៅពេលមានកិច្ចនីតិវិធីពីដើមដំបូង។

ii. កង្វះនៃរបកគំហើញនូវអង្គហេតុថ្មីមិនត្រូវកើតឡើងដោយសារកង្វះនៃការយកចិត្តទុកដាក់សមហេតុផលពីសំណាក់ភាគីដើមបណ្ដឹងឡើយ។

---

[3] *ករណីរបស់ អៀង សារី* ពាក្យសុំឱ្យពិចារណាឡើងវិញអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងជូនអង្គបុរេជំនុំជម្រះ សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣) ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ ERN 00198482-00198487, C22/I/53 ។

[4] លក្ខន្តិកៈច្បាប់តុលាការយុត្តិធម៌អន្តរជាតិ ឧបសម្ពន្ធភ្ជាប់ជាមួយធម្មនុញ្ញអង្គការសហប្រជាជាតិ មាត្រា៦១(១)។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការដាក់ពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឱ្យពិចារណាឡើងវិញ

iii. ភាគីដើមបណ្តឹងត្រូវបង្ហាញថាអង្គហេតុថ្មីអាចជាកត្តាកំណត់ក្នុងការឈាន ដល់សេចក្តីសម្រេចកាលពីដើមដំបូង។[5]

៥. ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះមិនបំពេញទៅតាមការញែកធាតុក្នុងរឿងក្តី *Barayagwiza* នេះឡើយ។ជាពិសេស៖

i. វាមិនបាននាំមកនូវអង្គហេតុថ្មីជូនដល់អង្គជំនុំជម្រះឡើយ ហើយដែលពុំមាននៅក្នុងសំណុំរឿង មុនពេលមានសេចក្តីសម្រេចដែលមានការតវ៉ានេះឡើយ។ ពាក្យស្នើសុំនេះនិយាយថាអង្គហេតុ ថ្មីទាក់ទងនឹងការបកស្រាយអំពីលក្ខខណ្ឌនៃលិខិតប្រគល់សិទ្ធិអំណាចគាំទ្រដល់មេធាវីរបស់ គាត់។ លិខិតប្រគល់សិទ្ធិអំណាចនេះត្រូវបានដាក់ចូលក្នុងសំណុំរឿងតាំងពីថ្ងៃ ទី៣០ ខែមករា ឆ្នាំ២០០៨ មកម្ល៉េះ ហើយដូច្នេះវាមិនមែនជាអ្វីដែល*ថ្មី* ទេ។ ហេតុដូចនេះ នៅក្នុងពាក្យ ស្នើសុំនោះគ្មានអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីមិនបានដឹងនោះទេនៅពេលចេញសេចក្តីសម្រេច ដើមដំបូងនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨។

ii. ដោយហេតុថាគ្មានអង្គហេតុថ្មីនៅក្នុងការដាក់ពាក្យស្នើសុំនោះ ការវែកញែកអំពី ការយកចិត្តទុកដាក់ដោយសមហេតុផលនោះមិនសំខាន់ទេចំពោះការសម្រេចបែបនេះ។

iii. ជាថ្មីម្តងទៀតដោយសារថាគ្មានអង្គហេតុថ្មីនៅក្នុងការដាក់ពាក្យស្នើសុំនោះបញ្ហាដែល ថាវាជាកត្តាកំណត់ក្នុងការសម្រេចនោះគឺពុំកើតមានឡើយ។

៦. ហេតុដូចនេះ សហព្រះរាជអាជ្ញាស្នើអង្គបុរេជំនុំជម្រះបដិសេធចោលនូវការដាក់ពាក្យស្នើ សុំនេះ។

## ៣.ច្បាប់ពាក់ព័ន្ធនឹងការតំណាង

*សិទ្ធិរបស់ភាគីមួយ(រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផង)ក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយ យុត្តិធម៌ គឺត្រូវបានធានា*

---

[5] ព្រះរាជអាជ្ញាទល់នឹង *Barayagwiza* សេចក្តីសម្រេចស្តីពីសំណើរបស់ព្រះរាជអាជ្ញាសុំឲ្យពិនិត្យឬពិចារណាឡើងវិញ សំណុំរឿងលេខ ICTR-97-19-AR72 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ កថាខ័ណ្ឌ៣៧-៣៩

៧. អង្គបុរេជំនុំជម្រះបានរកឃើញថាវិធាន៧៧(១០)("ហៅថាវិធាន")[6] មិនអនុញ្ញាតឱ្យដើមបណ្ដឹងរដ្ឋប្បវេណីថ្លែងទៅកាន់អង្គជំនុំជម្រះដោយផ្ទាល់ឡើយ[7]។ ដោយផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាសូមដាក់ជូននូវការលើកឡើងនូវអង្គច្បាប់ដូចខាងក្រោមនេះ ដើម្បីជួយដល់អង្គបុរេជំនុំជម្រះក្នុងការសម្រេចទៅលើការដាក់ពាក្យស្នើសុំនេះ។

៨. នៅក្នុង *ករណីរបស់នួន ជា*[8] អង្គបុរេជំនុំជម្រះ បានកត់សំគាល់ទៅលើមាត្រា៣៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក ដែលចែងថា តុលាការនេះត្រូវធានាឱ្យមានកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ និងឆាប់រហ័ស ដោយមាន *ការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ* និងសាក្សី[9] ។

៩. ស្រដៀងគ្នានឹងតុលាការនេះដែរ សាលាក្ដីអន្តរជាតិនានាបានទទួលស្គាល់នូវសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ ដោយរាប់បញ្ចូលទាំងលទ្ធភាពរបស់គូភាគីក្នុងការចូលរួមយ៉ាងពេញលេញក្នុងករណីរបស់ខ្លួនផ្ទាល់ ។ ជាទូទៅ សិទ្ធិនេះរាប់បញ្ចូលទាំងសិទ្ធិធ្វើស្វ័យតំណាង ។ ក្នុងករណី *Milosevic,* តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី ("ICTY") បានធ្វើការបដិសេធមិនដាក់ឱ្យមានមេធាវីសម្រាប់ចុងចោទទេដោយអះអាងថាខ្លួនធ្វើដូច្នេះមិនប្រឆាំងនឹងឆន្ទៈរបស់គាត់ទេ និងថា តាមធម្មតាការធ្វើដូច្នេះវាមិនសមស្របឡើយ[10] ។

---

[6] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក វិសោធនកម្មលើកទី១ ១ កុម្ភៈ ២០០៨ [ហៅថាវិធានបន្ទាប់ពីនេះទៅ]

[7] *ករណីរបស់ អៀង សារិ* សេចក្ដីសម្រេចអំពីកិច្ចការបឋមដែលបានលើកឡើងដោយមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងបណ្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់អៀង សារី សំណុំរឿងលេខ០០២/១៩-០៩-២០០៧-*អវតក/កសចស(អបជ០៣) ចុះថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០០៨* ERN00198102, C22/I/46 *កថាខណ្ឌ ៨* [ចាប់ពីពេលនេះទៅហៅថា សេចក្ដីសម្រេចអំពីកិច្ចការបឋម]។

[8] *ករណីរបស់ នួន ជា* សេចក្ដីសម្រេចអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្ដោះអាសន្ន, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០១) ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ ERN 00172866-00172906, C11/53 កថាខ័ណ្ឌ 19 [*ចាប់ពីពេលនេះទៅហៅថា* សេចក្ដីសម្រេចអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី] ។

[9] ច្បាប់ អ.វ.ត.ក មាត្រា៣៣(ថ្មី) ។

[10] *រដ្ឋអាជ្ញា ទល់នឹង Milosevic,* មូលហេតុសំរាប់សេចក្ដីសម្រេចអំពីការចាត់តាំងមេធាវីការពារក្ដី, សំណុំរឿងលេខ: IT-02-54-T, ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៤, កថាខ័ណ្ឌ ៧ [*ចាប់ពីពេលនេះទៅហៅថា* សេចក្ដីសម្រេច Milosevic] ។

ជាថ្មីម្តងទៀត *នៅក្នុងករណី Seselj* តុលាការ ICTY បានសំរេចថាចុងចោទមានសិទ្ធិអនុវត្ត កិច្ចការពារខ្លួនដោយខ្លួនឯងបាន ហើយការជ្រៀតជ្រែកចំពោះសិទ្ធិនេះត្រូវមានកម្រិត[11]។ តុលាការបានរកឃើញថានិយាមសិទ្ធិមនុស្សធានាទាំង សិទ្ធិធ្វើស្វ័យតំណាង *និង* សិទ្ធិមាន ជំនួយផ្នែកច្បាប់[12] ។

*សិទ្ធិធ្វើស្វ័យតំណាង មិនមែនជាសិទ្ធិដាច់ខាតទេ*

១០. សិទ្ធិធ្វើស្វ័យតំណាង ទោះជាយ៉ាងណាក៏ដោយ មិនមែនជាសិទ្ធិដាច់ខាតទេ[13] ។ ឧទាហរណ៍ យុត្តាធិការនៃប្រព័ន្ធច្បាប់ស៊ីវិលជាក់លាក់មួយចំនួនជារួមអនុញ្ញាតឲ្យមានការចាត់តាំងមេធាវី តាមអាណត្តិ[14] ។ នៅក្នុងករណីជាច្រើន សិទ្ធិធ្វើស្វ័យតំណាងមិនបានរារាំងតុលាការអន្តរជាតិ មិនឲ្យដាក់មេធាវីប្រចាំការឡើយ[15] ។ មានគ្រាមួយ តុលាការ ICTY បានកំណត់និយមន័យ អំពីតួនាទីរបស់មេធាវីប្រចាំការ ដោយរាប់បញ្ចូលទាំង សមត្ថភាពក្នុងការគ្រប់គ្រងនូវកិច្ចការ ពារខ្លួនពីចុងចោទដែលបានធ្វើស្វ័យតំណាង នៅក្នុងកាលៈទេសៈពិសេស បើសិនចុងចោទបាន "ចូលរួមពាក់ព័ន្ធនៅក្នុងការអនុវត្តន៍ដែលមានការរំខានដែលតម្រូវឲ្យមានការបណ្តេញរូប គាត់ចេញពីសាលសវនាការជាដើម[16] ។

១១. ស្វ័យតំណាងអាចត្រូវបានគេបដិសេធផងដែរ ហើយមេធាវីតាមអាណត្តិត្រូវបានគេចាត់តាំង ប្រសិនបើមានតម្រូវការខាងផ្នែកយុត្តិធម៌[17]។ ឃ្លាដែលថា "ប្រយោជន៍យុត្តិធម៌" មានវិសាលភាព

---

[11] *ព្រះរាជអាជ្ញា ទល់នឹង Seselj,* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ស្នើសុំឲ្យបង្គាប់តែងតាំងស្នាក្តីដើម្បីមេធាវីការពារក្តីរបស់ Vojislav Seselj, សំណុំរឿងលេខ: IT-03-67-PT, ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៣, កថាខ័ណ្ឌ ១៥ [*ចាប់ពីពេលនេះទៅហៅថា* សេចក្តីសម្រេច Seselj] ។

[12] សេចក្តីសម្រេច Seselj, កថាខ័ណ្ឌ ១៨ ។

[13] សេចក្តីសម្រេច Seselj, កថាខ័ណ្ឌ ២០ ។

[14] សេចក្តីសម្រេច Seselj, កថាខ័ណ្ឌ ១៦ ។

[15] សេចក្តីសម្រេច Seselj, កថាខ័ណ្ឌ ១៥ ។

[16] សេចក្តីសម្រេច Seselj, កថាខ័ណ្ឌ ៣០ ។

[17] សេចក្តីសម្រេច Seselj, កថាខ័ណ្ឌ ២០ ។

ទូលំទូលាយ ។ វារាប់បញ្ចូលទាំងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវ ដែលប្រការនេះមិនគ្រាន់តែជាសិទ្ធិជាមូលដ្ឋានរបស់ចុងចោទតែម្នាក់ឯងនោះទេ ប៉ុន្តែថែមទាំងជាផលប្រយោជន៍ជាមូលដ្ឋានសម្រាប់តុលាការផងដែរ[18]។ ដោយការទទួលស្គាល់ពីផលប្រយោជន៍នេះតាមរយៈករណី *Milosevic*[19] ICTY បានបញ្ជាក់អះអាងថាទាំងយុត្តិសាស្ត្ររបស់ខ្លួនផ្ទាល់ និងទាំងរបស់តុលាការអន្តរជាតិដទៃទៀតបានទទួលស្គាល់ថាវាអាចសមស្របសំរាប់ពួកគេដែលត្រូវប្រកាន់យកថាមេធាវីគឺជាអ្នកបង្ហាញភស្តុតាងមិនមែនចុងចោទទេ និងថា សេចក្តីសម្រេចដូច្នេះគួរតែកើតឡើងទៅតាមករណីនីមួយៗ[20] ។

*ភាគីមួយអាចចែករំលែកពេលវេលាសវនាការជាមួយមេធាវីរបស់ខ្លួនបាន*

១២. ដូចតុលាការនេះដែរ តុលាការមួយមានអំណាចក្នុងការអនុញ្ញាតឲ្យមេធាវីណាម្នាក់អនុវត្តករណីណាមួយទាំងមូល ឬអនុញ្ញាតឲ្យចុងចោទណាម្នាក់ ចូលរួមផងដែរ ដោយការបង្ហាញខ្លួនដោយផ្ទាល់តែមួយចំណែកណាមួយ ។ ការចាត់ចែងបែបណាក៏ដោយ គឺធ្វើឡើងដើម្បីឲ្យតុលាការកំណត់អំពីស្ថានភាពជុំវិញទាំងអស់ ដោយរាប់បញ្ចូលទាំងស្ថានភាពនានាដែលកើតមានឡើងនៅក្នុងកិច្ចដំណើរការនីតិវិធីនិងស្ថានភាពផ្ទាល់ខ្លួនរបស់ចុងចោទ[21]។ ផ្ទុយមកវិញ តុលាការពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូន("SCSL")បានទទួលស្គាល់ថា វាអាចមានស្ថានភាពផ្សេងៗដែលថាវាមានលក្ខណៈសមស្រប និងជាសមត្ថកិច្ចរបស់តុលាការមួយក្នុងការទាមទារថា ករណីមួយត្រូវតែធ្វើតំណាងដោយមេធាវីណាម្នាក់ និងមិនមែនដោយចុងចោទនោះទេ ។ ស្ថានភាពបែបនេះដែលត្រូវបានគេចាត់ទុកថាសមស្របអាចត្រូវបានកំណត់ទៅតាមភាពជាក់ស្តែងនៃរឿងក្តីនីមួយៗដោយ

---

[18] សេចក្តីសម្រេច Seselj, កថាខ័ណ្ឌ ២១ ។

[19] *Milosevic ទល់នឹង រដ្ឋអាជ្ញា,* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទុំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះអំពីការចាត់តាំងមេធាវីការពារក្តី, សំណុំរឿងលេខ: *IT-02-54-AR73.7*, ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤, កថាខ័ណ្ឌ ១៦ ។

[20] សេចក្តីសម្រេច Milosevic, កថាខ័ណ្ឌ ៣៨ ។

[21] សេចក្តីសម្រេច Milosevic, កថាខ័ណ្ឌ ៣៦ ។

យោងទៅតាមកត្តាផ្សេងៗដូចជាសមត្ថភាពរបស់ចុងចោទក្នុងការអនុវត្តន៍ករណីរបស់ខ្លួនរួមនឹងឥរិយាបថ និងសកម្មភាពរបស់ខ្លួន[22] ។

*សិទ្ធិរបស់ចុងចោទ*

*មានលក្ខណៈជាការបញ្ចុះបញ្ចូលនៅក្នុងការកំណត់អំពីសិទ្ធិនានារបស់ដើមបណ្តឹងរដ្ឋប្បវេណី*

១៣. សហព្រះរាជអាជ្ញាកត់សំគាល់ឃើញថា អង្គបុរេជំនុំជម្រះបានរកឃើញថា គូភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី មានគោលជំហរខុសៗគ្នា និងគ្មានគោលការណ៍ទូទៅសំរាប់ប្រព្រឹត្ត ឲ្យបានដូចៗគ្នាសំរាប់គូភាគីទាំងអស់ឡើយ[23] ។ បែបនេះហើយបានជាច្បាប់ដែលបានលើក ឡើងពីខាងលើទាក់ទិនទៅនឹងសិទ្ធិរបស់ចុងចោទ អាចមិនត្រូវបានគេអនុវត្តដោយស្មើភាពគ្នាចំពោះករណីរបស់គូភាគីឡើយ ។ ទោះជាយ៉ាងនេះក៏ដោយ សហព្រះរាជអាជ្ញាសូមលើក ឡើងថាច្បាប់ជាធរមានសម្រាប់អនុវត្តនៅតុលាការនេះ ទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធី និងបានផ្តល់នូវសិទ្ធិមួយចំនួនជូនពួកគេស្មើគ្នានឹងភាគីដទៃទៀតទាំងអស់ ។ ឧទាហរណ៍ វិធាន ២១ នៃវិធានផ្ទៃក្នុង មានចែង*នូវសិទ្ធិជាមូលដ្ឋាន* ដែលចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធ៖

> "(ច្បាប់) ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ [...] ក្នុងបរិបទនេះ ៖
>
> ក- ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ....

---

[22] *រដ្ឋអាជ្ញា ទល់នឹង Norman et al,* សេចក្តីសម្រេចលើពាក្យសុំរបស់ Samuel Hinga Norman ដែលស្នើសុំការធ្វើស្វ័យតំណាងនៅក្រោមមាត្រា១៧(៤) នៃច្បាប់លក្ខន្តិកៈរបស់តុលាការពិសេស, សំណុំរឿងលេខ: SCSL-04-14-T, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៤, កថាខ័ណ្ឌ ៨ ។

[23] សេចក្តីសម្រេចអំពីកិច្ចការបឋម, កថាខ័ណ្ឌ៣, ៤ ។

គ- អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារពេញមួយអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី...” ។

១៤. ដោយគូសបញ្ជាក់អំពីសារៈសំខាន់នៃដើមបណ្តឹងរដ្ឋប្បវេណី វិធាន២៣ ចែងថា គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក គឺដើម្បីចូលរួមនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ។ នៅក្នុងលក្ខណៈដូចគ្នានេះដែរ អង្គបុរេជំនុំជម្រះ បានទទួលស្គាល់ថា អនុលោមតាមវិធាន ២៣.១(ក) ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនៅក្នុងគ្រប់ដំណាក់កាល *ទាំងអស់* នៃនីតិវិធីព្រហ្មទណ្ឌ រួមទាំងនៅក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គជំនុំជម្រះនេះផង[24] ។

១៥. ដោយសារតែតួនាទីដ៏ពិសេសរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលស្គាល់ដោយតុលាការនេះ សហព្រះរាជអាជ្ញា សូមជូនជាមតិថា សូមឲ្យអង្គបុរេជំនុំជម្រះ ពិនិត្យផ្អែកទៅតាមគោលការណ៍ច្បាប់ដែលគ្រប់គ្រងទៅលើសិទ្ធិរបស់ចុងចោទ ស្តីពីការធ្វើជាតំណាងដោយខ្លួនឯង ដើម្បីធ្វើជាមូលដ្ឋានក្នុងការសម្រេចអំពីសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលសវនាការដែលស្ថិតនៅចំពោះមុខអង្គបុរេជំនុំជម្រះ ។

*អំពីសិទ្ធិសវនាការដោយផ្ទាល់ថ្លែងទៅនឹងអំណាចរបស់ អង្គបុរេជំនុំជម្រះ ក្នុងការគ្រប់គ្រងដំណើរការនីតិវិធី*

១៦. តុលាការនេះ គឺជាតុលាការទី១ និងជាតុលាការអន្តរជាតិ ឬតុលាការដែលធ្វើឲ្យមានលក្ខណៈអន្តរជាតិតែមួយគត់ ដែលបានយល់ព្រមទទួលស្គាល់ឋានៈរបស់ជនរងគ្រោះទាំងឡាយនៃអំពើឧក្រិដ្ឋកម្មនានាថាគឺជាភាគីមួយ[25]។ ផ្ទុយទៅវិញ តុលាការព្រហ្មទណ្ឌអន្តរជាតិចាត់ទុកជនរង

[24] សេចក្តីសម្រេចស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រង់កថាខណ្ឌ ៣៦។ (សង្កត់បញ្ជាក់សេចក្តីបន្ថែម)

[25] វិធានផ្ទៃក្នុង សទ្ទានុក្រម និយមន័យនៃពាក្យ ភាគី។

គ្រោះថា គឺគ្រាន់តែជា*អ្នកចូលរួម* តែប៉ុណ្ណោះ និងស្តាប់មតិយោបល់របស់ពួកគេនៅពេលណាដែល "បានសម្រេចថាមតិយោបល់ទាំងនោះសមស្រប"[26] ។

១៧. ការទទួលស្គាល់របស់តុលាការនេះ ចំពោះជនរងគ្រោះទាំងអស់ដោយចាត់ទុកថាជាភាគីនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីគឺដោយផ្អែកទៅលើការពិនិត្យពិចារណាទៅតាមច្បាប់និងគោលការណ៍យ៉ាងត្រឹមត្រូវ ។ ជនរងគ្រោះទំនងជាបានដឹងព័ត៌មានយ៉ាងប្រសើរបំផុតអំពីប្រភេទ និង វិសាលភាពនៃឧក្រិដ្ឋកម្មទាំងនោះ។ ការចូលរួមរបស់ពួកគេនាំមកឱ្យតុលាការនេះនូវការដឹងជាដំបូងគេបង្អស់អំពីព្រឹត្តិការណ៍ និងអំពីនិងទស្សនៈវិស័យរបស់មនុស្សម្នាក់ទៅលើព្រឹត្តិការណ៍ទាំងនោះ ។ ជាក់ស្តែង ជនរងគ្រោះទាំងនោះ-គឺជាអ្នកដែលអាចផ្តល់ព័ត៌មានផ្សេងៗដល់តុលាការបានប្រសើរជាងជនដទៃណាទៀតទាំងអស់អំពីបញ្ហានៃការប៉ះទង្គិច យ៉ាងខ្លាំងរបស់ជនរងគ្រោះ និងសាក្សីនានា អំពីការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ ការជះឥទ្ធិពលទៅលើជនរងគ្រោះនិងសាក្សីការបំផ្លាញភស្តុតាងនិងអំពីបញ្ហាផ្សេងៗដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងចំណាត់ការនៃនីតិវិធីនៅមុនពេលជំនុំជម្រះក្តី ។ ការចូលរួមរបស់ ពួកគេនៅក្នុងដំណាក់កាលនេះ គឺកាន់តែមានសារៈសំខាន់ថែមទៀតនៅពេលតុលាការធ្វើការសម្រេចដោយផ្អែកលើអង្គហេតុជាក់ស្តែងទៅលើបញ្ហាទាំងនោះជាជាងដល់ដំណាក់កាលសវនាការ ដែលតុលាការត្រូវធ្វើការពិនិត្យពិចារណាទៅលើរាល់ភស្តុតាងទាំងអស់ផ្អែកលើបទដ្ឋាន *លើសពីវិមតិសង្ស័យ*[27] ។ ក្នុងកំរិតដែលទូលំ ទូលាយជាងនេះការចូលរួមរបស់ជនរងគ្រោះ គឺនាំមកនូវជំនឿទុកចិត្តទៅលើដំណើរការ នីតិវិធីព្រហ្មទណ្ឌដើរតួនាទីដ៏សំខាន់បំផុតនៅក្នុងការអប់រំ និងរួមចំណែកនៅក្នុងការផ្សះផ្សាក្នុងសង្គមមួយនៅពេលក្រោយជម្លោះ[28] ។

---

[26] លក្ខន្តិកៈនៃទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ គ្រង់មាត្រា៦៨.៣ ។

[27] ជាពិសេស នៅក្នុងពេលសម្រេចលើបញ្ហាផ្សេងៗផ្អែកតាមវិធាន៦៣.៣(ក) និង (ខ)។

[28] សូមអាន ជាទូទៅនៅក្នុងករណីរឿងក្តីរបស់ C Stahn, H Olasolo និង K Gibson *ការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធីបុរេ-ជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)* ចុះថ្ងៃទី១ មេសា ២០០៦ ទស្សនាវដ្តីនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ លេខ ៤២ (២១៩) [*ដែលតមកទៀតនៅក្នុងនេះហៅថា* Stahn *និងគូរកន*] នៅត្រង់លេខយោងជើងទំព័រលេខ ១០។

១៨. ក៏ប៉ុន្តែ ដើម្បីផ្តល់ប្រសិទ្ធិភាពឲ្យបានពេញលេញដល់អាណត្តិរបស់តុលាការនេះ អង្គបុរេជំនុំជម្រះត្រូវតែធ្វើការថ្លឹងថ្លែងមួយផ្អែកអំពីសិទ្ធរបស់ជនរងគ្រោះសក្តានុពលដែលមានចំនួនដ៏ច្រើនដើម្បីបានចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការនីតិវិធីផ្សេងៗ-គឺជាសិទ្ធិដែលត្រូវតែរក្សាការពារដោយមិនអាចប្រកែកបាន ដូចដែលមានចែងនៅក្នុងវិធានស្រាប់ហើយដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់សិទ្ធិមនុស្ស - និងម្ខាងទៀតគឺ សិទ្ធិរបស់ចុងចោទនានាដែលត្រូវតែបានទទួលនូវការជំនុំជម្រះក្តីប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌ និងដោយឆាប់រហ័សតាមសមហេតុសមផល ។ យុត្តិសាស្ត្រអន្តរជាតិនិងទម្លាប់អនុវត្តរបស់ថ្នាក់ជាតិចែងថា តុលាការទាំងឡាយអាចគ្រប់គ្រងទៅលើការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់របស់ខ្លួនបានដើម្បីធ្វើឲ្យមានតុល្យភាពតាមផ្លូវតុលាការរវាងការចាំបាច់ខានមិនបានទាំងពីរនេះ[29] ។ សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គបុរេជំនុំជម្រះធ្វើការបកស្រាយអំពីកំរិតនៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី (រួមទាំងសិទ្ធិរបស់ពួកគេក្នុងការលើកឡើងនូវមតិយោបល់ផ្សេងៗដោយខ្លួនគេផ្ទាល់ផង) នៅក្នុងលក្ខខណ្ឌដែលស្រដៀងគ្នានេះ[30] ។ បើសិនជាមាន ភាពផ្ទុយគ្នា ជាក់ស្តែង ឬជាសំខាន់ណាមួយរវាងវិធាន២៣.៧ ដ៏សំខាន់ និងទូលាយ ទៅនិង វិធាន៧៧.១០ ដែលនីតិវិធីមានការដាក់កម្រិត ត្រូវតែបានធ្វើការពិនិត្យបកស្រាយដើម្បីជាប្រយោជន៍ដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ ជាងនេះទៅទៀត ការភ័យខ្លាចអំពីមានការរំលោភបំពានណាមួយទៅលើសិទ្ធិទាំងនោះអាចមិនមែនជាហេតុផលនៃការផុតរលត់របស់សិទ្ធិទាំងនោះទេនៅពេលដែលមានការតម្រូវជាក់ស្តែងណាមួយអំពីការដាក់កម្រិតដើម្បីធានា មិនឲ្យមានការរំលោភដំណើរការនីតិវិធី[31] ។

[29] Stahn *et al* មាត្រា ទំព័រទី២-៣។

[30] អនុលោមតាមវិធាន២១ វិធាន២៣ ជាដើម។ល។

[31] សូមអានករណីរឿងក្តីរបស់ Nina H B Jorgensen បញ្ហាអំពីការតំណាងដោយខ្លួនឯងនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនានា CIJ 4 1 (64), ចុះថ្ងៃទី១ មីនា ២០០៦ ត្រង់ទំព័រ ៨។

## ៤. សំណើ

១៩. សហព្រះរាជអាជ្ញាសូមធ្វើការសន្និដ្ឋានថាអង្គហេតុដែលមាននៅក្នុងពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនមានយុត្តិកម្មក្នុងការបើកឡើងវិញនូវសវនាការបណ្តឹងឧទ្ធរណ៍អំពីការឃុំខ្លួនបណ្តោះអាសន្ន ឬ សវនាការបណ្តឹងឧទ្ធរណ៍អំពីយុត្តាធិការឡើយ។ ហេតុដូចនេះ សហព្រះរាជអាជ្ញាស្នើឱ្យអង្គបុរេជំនុំជម្រះប្រកាសបិទផ្លូវកុំឱ្យមានសវនាការបែបនេះ។

២០. ប៉ុន្តែដើម្បីជាប្រយោជន៍ដល់សវនាការផ្សេងៗទៀតនៅថ្ងៃអនាគតអង្គបុរេជំនុំជម្រះអាចពិចារណាបង្កើតឱ្យមានគោលការណ៍ណែនាំផ្សេងៗសំរាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឱ្យមានតុល្យភាពនៃសិទ្ធិរបស់ជនរងគ្រោះសក្តានុពលជាច្រើននាក់ដើម្បីពួកគេបានចូលរួមប្រកបដោយអត្ថន័យនៅក្នុងកិច្ចដំណើរការនីតិវិធី និង សិទ្ធិរបស់ចុងចោទទទួលបាននូវកិច្ចដំណើរការនីតិវិធីដោយត្រឹមត្រូវនិងឆាប់រហ័សហើយសមហេតុផល។ គោលការណ៍ទាំងនោះអាចរាប់បញ្ចូលទាំងសិទ្ធិបញ្ញត្តិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីស្របច្បាប់ដែលគ្មានអ្នកតំណាងសំរាប់ថ្លែងចំពោះមុខអង្គជំនុំជម្រះដោយខ្លួនឯងផ្ទាល់ ។

២១. សហព្រះរាជអាជ្ញាកត់សម្គាល់ថាកិច្ចប្រជុំពេញអង្គរបស់ចៅក្រមនឹងធ្វើឡើងនៅខែកញ្ញាឆ្នាំ២០០៨ហើយអាចត្រូវបានសុំឱ្យដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធតាមរយៈអំណាចធ្វើវិធានរបស់ខ្លួន។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨
សហព្រះរាជអាជ្ញា

លោកស្រី ជា លាង លោក Robert PETIT